**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ:......[illegible]......
មកដល់ថ្ងៃទី០៤ ខែ០៤ ឆ្នាំ២៥
ម៉ោង......០៧:១០......

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសារណៈ
- បានឃើញអនុក្រឹត្យលេខ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីគោលការណ៍ យន្តការ និងនីតិវិធីនៃការស្នើសុំ ការអនុម័ត និងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដើម្បីជំរុញនិងលើកកម្ពស់ប្រសិទ្ធភាព និងសមិទ្ធផលការងារនៅតាមក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល លើកលែងតែក្រសួងការពារជាតិ។

## ជំពូកទី២

## គោលការណ៍អនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

**មាត្រា២ .-**

ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំនីមួយៗ ផ្អែកលើគោលការណ៍សមិទ្ធកម្ម សង្គតិភាព សមធម៌ ប្រសិទ្ធភាព លទ្ធភាពនៃថវិកា និងចីរភាព ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើពីគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ហៅកាត់ថា "**គ.ប.ស.**"។

**មាត្រា៣ .-**

ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវដាក់ឱ្យអនុវត្តសម្រាប់ប្រភេទសមិទ្ធកម្មដូចខាងក្រោម៖

- ប្រភេទទី១ : ការវាយតម្លៃនិងលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល
- ប្រភេទទី២ : ការវាយតម្លៃនិងលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព និង
- ប្រភេទទី៣ : ការវាយតម្លៃនិងលើកទឹកចិត្តគាំទ្រសមិទ្ធកម្មគម្រោង។

ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល អង្គភាព និងគម្រោង ត្រូវកំណត់និងកែប្រែដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមការស្នើសុំរបស់ប្រធាន **គ.ប.ស.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## យន្តការគ្រប់គ្រង និងអនុវត្ត

## ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

### ផ្នែកទី១

### យន្តការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

**មាត្រា៤ .-**

ត្រូវបានបង្កើត គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការដឹកនាំនិងគ្រប់គ្រងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។

**គ.ប.ស**. មានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធាន
- រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ អនុប្រធានប្រចាំការ
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប អនុប្រធាន
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអធិការកិច្ច ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការ។

សមាសភាពជាក់ស្តែងនៃ **គ.ប.ស**. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**គ.ប.ស**. មានភារកិច្ចដូចតទៅ៖

- ផ្សព្វផ្សាយគោលការណ៍ នីតិវិធី និងបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- រៀបចំលិខិតបទដ្ឋាន និងសេចក្តីណែនាំគាំទ្រដល់ការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ពិនិត្យសំណើគម្រោងអនុវត្តប្រព័ន្ធលើទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន និងលើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យនិងសម្រេច
- រៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យដំណើរការប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ក្នុងរដ្ឋបាលសាធារណៈសម្រាប់ឆ្នាំនីមួយៗ បន្ទាប់ពីទទួលបានការសម្រេចជាគោលការណ៍ពីរាជរដ្ឋាភិបាល
- ចុះកិច្ចព្រមព្រៀងអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មជាមួយប្រធានគណៈកម្មការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈក្រសួង ស្ថាប័ន
- បើកផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មដល់គណៈកម្មការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈក្រសួង ស្ថាប័ន តាមរយៈប្រព័ន្ធធនាគារទៅក្នុងគណនីរបស់ក្រសួង ស្ថាប័ននីមួយៗ បន្ទាប់ពីបានចុះកិច្ចព្រមព្រៀងរួចរាល់
- ផ្តល់ជំនួយបច្ចេកទេសគាំទ្រដល់ការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ក្នុងរដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន
- ទទួលរបាយការណ៍ និងពិនិត្យវាយតម្លៃសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចផ្តល់ថវិកាលើកទឹកចិត្ត ផ្អែកលើការសម្រេចជាគោលការណ៍ពីរាជរដ្ឋាភិបាល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងធ្វើរបាយការណ៍បូកសរុបប្រចាំឆមាស និងប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល

- ស្នើសុំការសម្រេចជាគោលការណ៍ពីរាជរដ្ឋាភិបាល និងចាត់វិធានការកែលម្អការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ចងក្រងបទពិសោធ ចំណេះដឹង និងឧត្តមានុវត្តន៍នៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៦ .-**

**គ.ប.ស.** ត្រូវបង្កើតក្រុមការងារ ដើម្បីគាំទ្រការអនុវត្តភារកិច្ចរបស់ខ្លួនដូចខាងក្រោម៖

- ក្រុមការងារបច្ចេកទេស
- ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃ
- ក្រុមការងារដោះស្រាយបណ្តឹងតវ៉ា។

**គ.ប.ស.** អាចបង្កើតក្រុមការងារផ្សេងទៀតតាមការចាំបាច់។

ការបង្កើតក្រុមការងារ ការតែងតាំងសមាសភាព ព្រមទាំងការកែសម្រួលសមាសភាពនិងតួនាទីភារកិច្ចរបស់ក្រុមការងារខាងលើ ត្រូវសម្រេចដោយប្រធាន **គ.ប.ស.**។

**មាត្រា៧ .-**

**គ.ប.ស.** អាចរៀបចំសេចក្តីណែនាំបន្ថែមដោយផ្អែកលើភាពចាំបាច់ ដើម្បីធានាបាននូវការអនុវត្តបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យនេះ។

## ផ្នែកទី២
## យន្តការគ្រប់គ្រង និងអនុវត្ត
## ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន

**មាត្រា៨ .-**

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាន លើកលែងក្រសួងការពារជាតិ ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈក្រសួង ស្ថាប័ន ហៅកាត់ថា "**គ.ប.ក.**" ដើម្បីអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័នសាមី។

**គ.ប.ក.** មានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រី ... ប្រធាន
- រដ្ឋលេខាធិការប្រចាំការ ... អនុប្រធាន
- រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មួយចំនួន ... សមាជិក
- អគ្គលេខាធិការ ឬអគ្គនាយកនៃអង្គភាពទទួលបន្ទុករដ្ឋបាលនិងហិរញ្ញវត្ថុ ឬអង្គភាពទទួលបន្ទុកធនធានមនុស្ស ... លេខាធិការ។

ប្រធាន **គ.ប.ក.** អាចចាត់តាំងសមាសភាពផ្សេងទៀតតាមការចាំបាច់ ជាសមាជិកនៃ **គ.ប.ក.**។

សមាសភាពជាក់ស្តែងនៃ **គ.ប.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ប.ក.**។

**មាត្រា៩ ..**

**គ.ប.ក.** មានភារកិច្ចដូចតទៅ៖

- ផ្សព្វផ្សាយគោលការណ៍ នីតិវិធី និងបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យស្ដីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដល់ថ្នាក់ដឹកនាំនិងមន្ត្រីក្រោមឱវាទ
- ណែនាំអង្គភាពចំណុះ រៀបចំសំណើគម្រោងសម្រាប់ការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ពិនិត្យបូកសរុបសំណើសុំអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់អង្គភាពចំណុះ និងស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល តាមរយៈ **គ.ប.ស.**
- ចុះកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយប្រធាន **គ.ប.ស.** និងចាត់វិធានការអនុវត្តកិច្ចព្រមព្រៀងឱ្យមានប្រសិទ្ធភាព
- ដឹកនាំនិងគ្រប់គ្រងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ក្នុងក្របខណ្ឌក្រសួង ស្ថាប័នរបស់ខ្លួន
- វាយតម្លៃ និងធ្វើសេចក្ដីសម្រេចលើលទ្ធផលនៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មសម្រាប់បុគ្គល អង្គភាព និងគម្រោង នៅក្នុងក្របខណ្ឌក្រសួង ស្ថាប័នរបស់ខ្លួន
- បូកសរុប និងរាយការណ៍លទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មដែលបានចុះជាមួយប្រធាន **គ.ប.ស.** និងស្នើសុំថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- ទទួល និងបែងចែកថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- ទទួលនិងដោះស្រាយព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ក្នុងក្របខណ្ឌក្រសួង ស្ថាប័នរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម និងអនុវត្តវិធានការកែលម្អ ព្រមទាំងរាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូន **គ.ប.ស.**
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ **គ.ប.ស.**។

**គ.ប.ក.** អាចបង្កើតក្រុមការងារ ឬអនុគណៈកម្មការនានា ដើម្បីគាំទ្រដល់ការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន តាមការចាំបាច់។

## ជំពូកទី៤
## នីតិវិធីស្នើសុំ និងអនុម័តដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

**មាត្រា១០ ..**

ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ត្រូវដាក់ពាក្យស្នើសុំការសម្រេចអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមរយៈ **គ.ប.ស.** ដើម្បីអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ យ៉ាងយូរត្រឹមសប្ដាហ៍ទី១ ខែមិថុនា នៃឆ្នាំនីមួយៗ។

ពាក្យស្នើសុំអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន ត្រូវមានភ្ជាប់ជាមួយនូវ៖

១- សំណើគម្រោងដោយបញ្ជាក់ពីការអនុវត្តសកម្មភាពដែលផ្សារភ្ជាប់នឹងការងារ ក្នុងគោលបំណង ជាយុទ្ធសាស្ត្រ ឬកម្មវិធីណាមួយរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖
   - ក្របខណ្ឌយុទ្ធសាស្ត្រ និងក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
   - គោលនយោបាយ ឬវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល
   - ផែនការយុទ្ធសាស្ត្រជាតិតាមវិស័យ
   - កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល
   - ផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន
   - វិធានការគោលនយោបាយជាក់លាក់ដែលរាជរដ្ឋាភិបាលតម្រូវឱ្យអនុវត្ត។

២- សំណើសុំថវិកាដោយមានបញ្ជាក់អំពីប្រភេទសមិទ្ធកម្ម និងស្ថានភាពនៃប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មដែលបាននិងកំពុងអនុវត្តនៅតាមក្រសួង ស្ថាប័នសាមី។

ក្រសួង ស្ថាប័នត្រូវបំពេញពាក្យសុំតាមទម្រង់ ដែលកំណត់ដោយ **គ.ប.ស.**។

**មាត្រា១១ .-**

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាន អាចស្នើសុំគោលការណ៍អនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ទាំងបីប្រភេទ ឬប្រភេទណាមួយ ដោយអនុលោមតាមមាត្រា១០ នៃអនុក្រឹត្យនេះ។ ការស្នើសុំដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងប្រភេទនីមួយៗ ត្រូវធ្វើដាច់ដោយឡែកពីគ្នា។

**មាត្រា១២ .-**

បន្ទាប់ពីទទួលបានពាក្យសុំពីទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាន **គ.ប.ស.** ត្រូវពិនិត្យសិក្សា វាយតម្លៃ និងលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេចផ្តល់ការអនុញ្ញាតជាគោលការណ៍។

**គ.ប.ស.** ត្រូវជូនដំណឹងដល់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋានសាមី បន្ទាប់ពីទទួលបានការសម្រេចពីរាជរដ្ឋាភិបាលលើសំណើដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។

**មាត្រា១៣ .-**

បន្ទាប់ពីបានទទួលការសម្រេចអនុញ្ញាតពីរាជរដ្ឋាភិបាល ប្រធាន **គ.ប.ក.** ត្រូវចុះកិច្ចព្រមព្រៀងអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មជាមួយប្រធាន **គ.ប.ស.** តាមទម្រង់កំណត់ដោយ **គ.ប.ស.**។

## ជំពូកទី៥
## ការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
### ផ្នែកទី១
### ការអនុវត្តការវាយតម្លៃ និងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល

**មាត្រា១៤ .-**

ការវាយតម្លៃ និងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល ត្រូវអនុវត្តដូចខាងក្រោម៖

១- ការជ្រើសរើស និងការចុះកិច្ចព្រមព្រៀងសមិទ្ធកម្មបុគ្គល។

២- ការអនុវត្តការវាយតម្លៃសមិទ្ធកម្មបុគ្គល។

៣- ការសម្រេចផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល។

**មាត្រា២០ .-**

**គ.ប.ក.** ត្រូវបូកសរុបលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្មបុគ្គលក្នុងក្រសួង ស្ថាប័នរបស់ខ្លួន និងផ្តល់របាយការណ៍ជូនប្រធាន **គ.ប.ស.** ពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មដែលបានចុះជាមួយប្រធាន **គ.ប.ស.** ដើម្បីស្នើសុំថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។

## អនុផ្នែកទី៣
## ការសម្រេចផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល

**មាត្រា២១ .-**

**គ.ប.ស.** ត្រូវបើកផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល ជូន **គ.ប.ក.** នៅរៀងរាល់ ៣(បី)ខែម្តង ដោយផ្អែកលើរបាយការណ៍សមិទ្ធកម្មរបស់ **គ.ប.ក.** និងតាមការកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មដែលបានចុះរវាងប្រធាន **គ.ប.ស.** និងប្រធាន **គ.ប.ក.**។

**មាត្រា២២ .-**

**គ.ប.ក.** ត្រូវបើកផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល ផ្អែកលើកម្រិតសមិទ្ធកម្មដែលសម្រេចបានដូចមានកំណត់ក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ តាមរយៈគណនីធនាគាររបស់សាមីជន។

**មាត្រា២៣ .-**

ចំនួនទឹកប្រាក់គោលសម្រាប់ការគណនាថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មបុគ្គល ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **គ.ប.ស.** និង **គ.ប.ក.**។

## ផ្នែកទី២
## ការអនុវត្តការវាយតម្លៃនិងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព

**មាត្រា២៤ .-**

ការវាយតម្លៃ និងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព ត្រូវអនុវត្តដូចខាងក្រោម៖

១- ការចុះកិច្ចព្រមព្រៀងអនុវត្តការវាយតម្លៃនិងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព។

២- ការអនុវត្តការវាយតម្លៃសមិទ្ធកម្មអង្គភាព។

៣- ការសម្រេចផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព។

## អនុផ្នែកទី១
## ការចុះកិច្ចព្រមព្រៀងអនុវត្តការវាយតម្លៃ និងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព

**មាត្រា២៥ .-**

ប្រធានអង្គភាព ដែលទទួលបានគោលការណ៍អនុញ្ញាតឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មសម្រាប់អង្គភាពរបស់ខ្លួន ត្រូវចុះកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយប្រធាន **គ.ប.ក.** ផ្អែកលើកិច្ចព្រមព្រៀងរវាង **គ.ប.ក.** និង **គ.ប.ស.**។ ការចុះកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តយ៉ាងយូរ ២(ពីរ)សប្តាហ៍ បន្ទាប់ពីការចុះកិច្ចព្រមព្រៀងរវាង **គ.ប.ក.** និង **គ.ប.ស.**។

**មាត្រា២៦ .-**

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ឬរដ្ឋលេខាធិការដ្ឋាន អាចស្នើសុំអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព សម្រាប់តែអង្គភាពជាអគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន ឬអង្គភាពថ្នាក់ប្រហាក់ប្រហែល អង្គភាពគាំទ្រគណៈកម្មាធិការកែទម្រង់របស់រាជរដ្ឋាភិបាល និងអង្គភាពទទួលបន្ទុកសវនកម្មផ្ទៃក្នុង។

## អនុផ្នែកទី១
## ការជ្រើសរើស និងការចុះកិច្ចព្រមព្រៀងសមិទ្ធកម្មបុគ្គល

**មាត្រា១៥ .-**

**គ.ប.ក.** អាចជ្រើសរើសបុគ្គលជាថ្នាក់ដឹកនាំ និង/ឬមន្ត្រី ក្នុង/ឬក្រៅក្រសួង ស្ថាប័នសាមី ដើម្បីចូលរួមអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ក្នុងការសម្រេចនូវគោលបំណងនៃគោលនយោបាយជាអាទិភាពរបស់ខ្លួន ដោយអនុលោមតាមមាត្រា១០ នៃអនុក្រឹត្យនេះ និងគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ជាបុគ្គលដែលបាននិងកំពុងឬនឹងទទួលបន្ទុកអនុវត្តការងារគន្លឹះនិងជាអាទិភាព ស្របតាមគោលបំណងជាយុទ្ធសាស្ត្រ ឬកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ
- ជាបុគ្គលមានសមត្ថភាពខ្ពស់ សមស្របសម្រាប់ការបំពេញការងារជាយុទ្ធសាស្ត្រ ឬកម្មវិធីគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ។

**មាត្រា១៦ .-**

បុគ្គលជាថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់មុខតំណែងដែលចូលរួមអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវចុះកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយប្រធាន **គ.ប.ក.**។

## អនុផ្នែកទី២
## ការវាយតម្លៃសមិទ្ធកម្មបុគ្គល

**មាត្រា១៧ .-**

ការវាយតម្លៃសមិទ្ធកម្មបុគ្គល ត្រូវអនុវត្តដោយ **គ.ប.ក.** រៀងរាល់ ៣(បី)ខែ ដោយផ្អែកលើសមិទ្ធកម្មធៀបនឹងសូចនាករកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មរវាងមន្ត្រីសាមីជាមួយប្រធាន **គ.ប.ក.**។

**មាត្រា១៨ .-**

ថ្នាក់ដឹកនាំនិងមន្ត្រីដែលត្រូវទទួលការវាយតម្លៃសមិទ្ធកម្ម ត្រូវផ្តល់របាយការណ៍សមិទ្ធកម្មជូនប្រធាន **គ.ប.ក.** នៅរៀងរាល់សប្តាហ៍ទី៤ នៃខែនីមួយៗ និងសប្តាហ៍ទី៤ នៃខែចុងក្រោយនៃត្រីមាសនីមួយៗ។

របាយការណ៍សមិទ្ធកម្មរបស់បុគ្គល ត្រូវរៀបចំតាមទម្រង់គំរូកំណត់ដោយ **គ.ប.ស.**។

**មាត្រា១៩ .-**

លទ្ធផលនៃការវាយតម្លៃសមិទ្ធកម្មរបស់ថ្នាក់ដឹកនាំនិងមន្ត្រីត្រូវបែងចែកជា៥ (ប្រាំ)កម្រិត ដូចខាងក្រោម៖

- កម្រិត១ : សមិទ្ធកម្មចាប់ពី ៩០% នៃគោលដៅកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្ម
- កម្រិត២ : សមិទ្ធកម្មចាប់ពី ៨០% ដល់ក្រោម ៩០% នៃគោលដៅកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្ម
- កម្រិត៣ : សមិទ្ធកម្មចាប់ពី ៧០% ដល់ក្រោម ៨០% នៃគោលដៅកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្ម
- កម្រិត៤ : សមិទ្ធកម្មចាប់ពី ៦០% ដល់ក្រោម ៧០% នៃគោលដៅកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្ម
- កម្រិត៥ : សមិទ្ធកម្មក្រោម ៦០% នៃគោលដៅកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្ម។

## អនុផ្នែកទី២
## ការវាយតម្លៃសមិទ្ធកម្មអង្គភាព

**មាត្រា២៧ .-**

ការវាយតម្លៃសមិទ្ធកម្មអង្គភាព ត្រូវអនុវត្តដោយ **គ.ប.ក.**។

**មាត្រា២៨ .-**

ការវាយតម្លៃសមិទ្ធកម្មរបស់អង្គភាព ត្រូវអនុវត្តផ្អែកលើលក្ខណវិនិច្ឆ័យគោលចំនួន ៦(ប្រាំមួយ) ដូចខាងក្រោម៖

១- ការរៀបចំនិងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាព។

២- ការរៀបចំនិងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍអង្គភាព។

៣- ការរៀបចំនិងដាក់ឱ្យអនុវត្តនិយាមប្រតិបត្តិរបស់អង្គភាព។

៤- ការបែងចែកការកិច្ចដល់គ្រប់មន្ត្រីនិងការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មរវាងអង្គភាព និងមន្ត្រី។

៥- ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមាននិងការបំពេញការងាររបស់មន្ត្រី។

៦- របាយការណ៍ប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងាររៀងរាល់ខែ។

ការវាយតម្លៃ និងការដាក់ពិន្ទុផ្អែកលើលក្ខណវិនិច្ឆ័យនៃការវាយតម្លៃសមិទ្ធកម្មរបស់អង្គភាព ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ **គ.ប.ស.**។

ការកែសម្រួលលក្ខណវិនិច្ឆ័យគោលខាងលើ សម្រាប់ការវាយតម្លៃសមិទ្ធកម្មអង្គភាព ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ **គ.ប.ស.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា២៩ .-**

**គ.ប.ក.** ពិនិត្យ វាយតម្លៃ និងសម្រេចលទ្ធផលនៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព និងផ្តល់របាយការណ៍វាយតម្លៃសមិទ្ធកម្មអង្គភាពចំណុះក្រសួង ស្ថាប័នរបស់ខ្លួនមក **គ.ប.ស.** នៅរៀងរាល់ឆមាស។

**មាត្រា៣០ .-**

លទ្ធផលនៃការវាយតម្លៃសមិទ្ធកម្មរបស់អង្គភាព ត្រូវបែងចែកជា ៥(ប្រាំ)កម្រិត ដូចខាងក្រោម៖

- កម្រិត១ : សមិទ្ធកម្មចាប់ពី ៩០% នៃគោលដៅកំណត់
- កម្រិត២ : សមិទ្ធកម្មចាប់ពី ៨០% ដល់ក្រោម ៩០% នៃគោលដៅកំណត់
- កម្រិត៣ : សមិទ្ធកម្មចាប់ពី ៧០% ដល់ក្រោម ៨០% នៃគោលដៅកំណត់
- កម្រិត៤ : សមិទ្ធកម្មចាប់ពី ៦០% ដល់ក្រោម ៧០% នៃគោលដៅកំណត់
- កម្រិត៥ : សមិទ្ធកម្មក្រោម ៦០% នៃគោលដៅកំណត់។

## អនុផ្នែកទី៣
## ការសម្រេចផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព

**មាត្រា៣១ .-**

ការផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព ត្រូវអនុវត្តមួយឆ្នាំមួយដង ផ្អែកលើលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្មអង្គភាព។

ចំនួនទឹកប្រាក់គោលសម្រាប់ការគណនាថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **គ.ប.ស.** និង **គ.ប.ក.**។

**មាត្រា៣២ .-**

**គ.ប.ស.** ត្រូវផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មអង្គភាព តាមរយៈ **គ.ប.ក.** នៅរៀងរាល់ចុងត្រីមាសទីបួន នៃឆ្នាំនីមួយៗ ដោយផ្អែកលើលទ្ធផលធៀបនឹងសូចនាករសមិទ្ធកម្ម។

ប្រធានអង្គភាព ត្រូវបែងចែកថវិកាគាំទ្រសមិទ្ធកម្មអង្គភាពដល់គ្រប់មន្ត្រីដែលបានចូលរួម ក្នុងការសម្រេចសមិទ្ធកម្មអង្គភាព ស្របតាមសមិទ្ធកម្មរបស់មន្ត្រីម្នាក់ៗ តាមរយៈគណនីធនាគាររបស់សាមីជន។

## ផ្នែកទី៣
## ការអនុវត្តការវាយតម្លៃនិងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មគម្រោង

**មាត្រា៣៣ .-**

ការវាយតម្លៃ និងការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មគម្រោង ក្នុងក្របខណ្ឌនៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវអនុវត្តដូចខាងក្រោមៈ

១- ការចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង។

២- ការអនុវត្តការវាយតម្លៃសមិទ្ធកម្មគម្រោង។

៣- ការសម្រេចផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មគម្រោង។

### អនុផ្នែកទី១
### ការចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង

**មាត្រា៣៤ .-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពគាំទ្រគណៈកម្មាធិការកែទម្រង់របស់រាជរដ្ឋាភិបាល និងប្រធានអង្គភាពទទួលបន្ទុកសវនកម្មផ្ទៃក្នុង ឬថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួង ស្ថាប័ន មានសិទ្ធិលើកសំណើសុំអនុវត្តគម្រោងមក **គ.ប.ក.** ដើម្បីស្នើសុំបន្តមក **គ.ប.ស.** ពិនិត្យស្នើសុំការសម្រេចជាគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ។

សំណើសុំអនុវត្តគម្រោង ត្រូវភ្ជាប់ជាមួយនូវផែនការសកម្មភាព ដែលមានកំណត់សូចនាករសមិទ្ធកម្ម និងពេលវេលាអនុវត្តច្បាស់លាស់ ព្រមទាំងការបែងចែកមន្ត្រីអនុវត្ត និងថវិកាសម្រាប់ការលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម និងបំពេញតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ និងតាមទម្រង់កំណត់ដោយ **គ.ប.ស.**។

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពគាំទ្រគណៈកម្មាធិការកែទម្រង់របស់រាជរដ្ឋាភិបាល និងប្រធានអង្គភាពទទួលបន្ទុកសវនកម្មផ្ទៃក្នុង ឬថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួង ស្ថាប័ន ជាអ្នកផ្តួចផ្តើមស្នើសុំអនុវត្តគម្រោង និងត្រូវទទួលស្គាល់ថាជាប្រធានគម្រោង។

**មាត្រា៣៥ .-**

ចំនួនទឹកប្រាក់គោល សម្រាប់ការគណនាថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៃការអនុវត្តគម្រោង ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **គ.ប.ស.** និង **គ.ប.ក.**។

**មាត្រា៣៦ .-**

ប្រធានគម្រោង ត្រូវចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយប្រធាន **គ.ប.ក.** ផ្អែកលើកិច្ចព្រមព្រៀងរវាង **គ.ប.ក.** និង **គ.ប.ស.**។ ការចុះកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តយ៉ាងយូរ ២(ពីរ)សប្តាហ៍ បន្ទាប់ពីការចុះកិច្ចព្រមព្រៀងរវាង **គ.ប.ក.** និង **គ.ប.ស.**។

## អនុផ្នែកទី២
## ការវាយតម្លៃសមិទ្ធកម្មគម្រោង

**មាត្រា៣៧ .-**

ការវាយតម្លៃសមិទ្ធកម្មគម្រោង ត្រូវអនុវត្តដោយ **គ.ប.ក.**។

**មាត្រា៣៨ .-**

ការវាយតម្លៃសមិទ្ធកម្មគម្រោង ត្រូវអនុវត្តផ្អែកលើសមិទ្ធកម្មគម្រោងជាក់ស្តែងធៀបនឹងសូចនាករសមិទ្ធកម្មគម្រោង ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងរវាង **គ.ប.ក.** និង **គ.ប.ស.**។

ប្រធានគម្រោង ត្រូវផ្តល់របាយការណ៍លទ្ធផលនៃការអនុវត្តគម្រោងមក **គ.ប.ក.** តាមរយៈលេខាធិការដ្ឋាននៃ **គ.ប.ក.** នៅតាមដំណាក់កាលទាំង ៤ (បួន) ដូចខាងក្រោម៖

- ដំណាក់កាលទី១ ពេលចាប់ផ្តើមអនុវត្តគម្រោង
- ដំណាក់កាលទី២ ពេលសម្រេចបាន ៥០% នៃសមិទ្ធកម្មដែលបានកំណត់
- ដំណាក់កាលទី៣ ពេលសម្រេចបាន ៨០% នៃសមិទ្ធកម្មដែលបានកំណត់
- ដំណាក់កាលទី៤ ពេលសម្រេចបាន ១០០% នៃសមិទ្ធកម្មដែលបានកំណត់។

**មាត្រា៣៩ .-**

**គ.ប.ក.** ត្រូវបូកសរុបរបាយការណ៍នៃការអនុវត្តគម្រោង និងផ្តល់របាយការណ៍ជូន **គ.ប.ស.** តាមដំណាក់កាលនៃការសម្រេចសមិទ្ធកម្មគម្រោង ដូចមានកំណត់ក្នុងមាត្រា៣៨ នៃអនុក្រឹត្យនេះ ដើម្បីទទួលបានថវិកាសម្រាប់លើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។

## អនុផ្នែកទី៣
## ការសម្រេចផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មគម្រោង

**មាត្រា៤០ .-**

**គ.ប.ស.** ត្រូវផ្តល់ថវិកាលើកទឹកចិត្តគាំទ្រសមិទ្ធកម្មគម្រោងជូនមន្ត្រីគម្រោងតាមរយៈ **គ.ប.ក.** ផ្អែកលើសមិទ្ធកម្មសម្រេចបានតាមដំណាក់កាលនៃការអនុវត្តគម្រោង ដែលមានកំណត់ក្នុងមាត្រា៣៨ នៃអនុក្រឹត្យនេះ ដូចខាងក្រោម៖

- ការចាប់ផ្តើមអនុវត្តគម្រោង ទទួលបានថវិកាចំនួន ២០% នៃថវិកាគម្រោង
- ការសម្រេចសមិទ្ធកម្មគម្រោង ៥០% ទទួលបានថវិកាបន្ថែមចំនួន ៣០% នៃថវិកាគម្រោង
- ការសម្រេចសមិទ្ធកម្មគម្រោង ៨០% ទទួលបានថវិកាបន្ថែមចំនួន ៣០% នៃថវិកាគម្រោង
- ការសម្រេចសមិទ្ធកម្មគម្រោង ១០០% ទទួលបានថវិកាបន្ថែមចំនួន ២០% នៃថវិកាគម្រោង។

ការបែងចែកថវិកាសមិទ្ធកម្មគម្រោង ត្រូវសម្រេចដោយប្រធានគម្រោងដោយផ្អែកលើសមិទ្ធកម្មរបស់មន្ត្រីអនុវត្តគម្រោងម្នាក់ៗ ដោយបើកផ្តល់តាមរយៈគណនីធនាគាររបស់សាមីជន។

## ជំពូកទី៦
## ប្រភពថវិកាសម្រាប់ការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

**មាត្រា៤១ .-**

ថវិកាគាំទ្រការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ជាថវិកាជាតិស្ថិតក្នុងកញ្ចប់ថវិកាដែលសម្រេចដោយរាជរដ្ឋាភិបាល។

## ជំពូកទី៧
## ការដោះស្រាយបណ្ដឹងតវ៉ា

**មាត្រា៤២ .-**

ថ្នាក់ដឹកនាំ និងមន្ត្រីអាចប្ដឹងតវ៉ាទៅ **គ.ប.ក.** ជាលាយលក្ខណ៍អក្សរ ក្នុងករណីសេចក្ដីសម្រេចនៃការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងក្រសួង ស្ថាប័នសាមី ប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់សាមីខ្លួន ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីសម្រេចពាក់ព័ន្ធនឹងសាមីខ្លួន។

**មាត្រា៤៣ .-**

នៅពេលទទួលបានពាក្យបណ្ដឹង **គ.ប.ក.** ត្រូវប្រើប្រាស់គ្រប់មធ្យោបាយក្នុងសមត្ថកិច្ចរបស់ខ្លួនដើម្បីដោះស្រាយបណ្ដឹងតវ៉ាឱ្យមានប្រសិទ្ធភាពខ្ពស់។ ការដោះស្រាយបណ្ដឹងតវ៉ា ត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់តាំងពីថ្ងៃដែលទទួលបានពាក្យបណ្ដឹង។

**មាត្រា៤៤ .-**

ក្នុងករណីមិនសុខចិត្តនឹងនីតិវិធីដោះស្រាយ ឬដំណោះស្រាយរបស់ **គ.ប.ក.** ម្ចាស់បណ្ដឹងអាចប្ដឹងបន្តទៅ **គ.ប.ស.** ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពី **គ.ប.ក.**។

**មាត្រា៤៥ .-**

**គ.ប.ស.** ត្រូវពិនិត្យដោះស្រាយ និងឆ្លើយតបជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ដឹង ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប)ថ្ងៃ បន្ទាប់ពីទទួលពាក្យប្ដឹងតវ៉ា។

## ជំពូកទី៨
## ទណ្ឌកម្មខាងវិន័យ

**មាត្រា៤៦ .-**

ត្រូវចាត់ទុកជាកំហុស ចំពោះថ្នាក់ដឹកនាំនិងមន្ត្រី ដែលបានប្រព្រឹត្ត ផ្ដើមគំនិត និង/ឬ សមគំនិតក្នុងការប្រព្រឹត្តអំពើដូចខាងក្រោម៖

- ការក្លែងបន្លំលិខិតស្នាម ឬឯកសារផ្សេងៗ ក្នុងគោលបំណងទទួលបានថវិកាលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម
- ការផ្ដល់ព័ត៌មានមិនពិតក្នុងគោលបំណងទទួលបានថវិកាលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម
- បង្វែរ ឬកេងប្រវញ្ចថវិកាលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មដែលត្រូវបែងចែកដល់មន្ត្រីចំណុះអង្គភាព
- មិនបានបែងចែកថវិកាលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មដល់មន្ត្រី តាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ
- រារាំង ឬព្យាយាមរារាំងដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាពនៃការអនុវត្តការវាយតម្លៃសមិទ្ធកម្ម
- ប្រព្រឹត្តអំពើផ្សេងៗទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

**មាត្រា៤៧ .-**

រាល់កំហុស ដូចមានកំណត់ក្នុងមាត្រា៤៦ ខាងលើ ត្រូវអនុវត្តទណ្ឌកម្មដូចមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៤៨ .-**

ក្រសួង ស្ថាប័ន ត្រូវបញ្ជូនសំណើសុំគោលការណ៍អនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ សម្រាប់ឆ្នាំ២០២៥ មក **គ.ប.ស.** ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៤៩ ៈ-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥០ ៈ-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ